ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

# ស្ដីពី

# មគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា

ខែសីហា ឆ្នាំ២០២១

# មាតិកា


**បុព្វកថា** ........ ii

**មាតិកា** ........ iii

**បុព្វកថា** ........ iii

**២ .ចក្ខុវិស័យ** ........ ២

**៣ .គោលបំណង និងគោលដៅ** ........ ២

**៤ .យុទ្ធសាស្ត្រ** ........ ២

៤.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ........ ២

៤.២. អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាល និងការទទួលស្គាល់គ្រូប្រឹក្សាតាមសាលារៀន ........ ៣

៤.៣. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ........ ៣

៤.៤. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតមធ្យមសិក្សា និងយុវជនក្រៅសាលា ........ ៣

៤.៥. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតឧត្តមសិក្សា ........ ៣

៤.៦. ពង្រឹងការចូលរួម គាំទ្រ និងលើកទឹកចិត្តពីអ្នកពាក់ព័ន្ធ ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ........ ៤

**៥ .ផែនការសកម្មភាព** ........ ៤

៥.១. ការបង្កើតយន្តការ ........ ៤

៥.២. ការបង្កើតក្របខណ្ឌគតិយុត្ត ........ ៤

៥.៣. ការគាំទ្រហិរញ្ញវត្ថុ ........ ៥

៥.៤. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ៥

**៦ .ការពិនិត្យតាមដាន និងការវាយតម្លៃ** ........ ៥

**៧ .សេចក្តីសន្និដ្ឋាន** ........ ៥

**សន្ទានុក្រម** ........ ៧

# បុព្វកថា

ស្ថិតក្នុងបរិការណ៍នៃការវិវត្តជាសកល ក្នុងយុគសម័យឌីជីថល និងបដិវត្តឧស្សាហកម្មទី៤ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត បានទទួលរងឥទ្ធិពលដែលនាំឱ្យមានបម្រែបម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ និងការលេចឡើងនូវនិន្នាការថ្មីក្នុងទីផ្សារកម្លាំងពលកម្ម ដែលបង្កើតឱ្យមានបញ្ហាកង្វះជំនាញ និងគម្លាតជំនាញ។ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយបញ្ហានេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីអាទិភាព សំដៅលើកកម្ពស់គុណភាពនៃការអប់រំ ពង្រឹងប្រសិទ្ធភាពនៃការចូលទីផ្សារការងារ និងលទ្ធភាពទទួលបានការងារធ្វើរបស់យុវជនក្រោយពេលបញ្ចប់ការសិក្សា។

គោលនយោបាយស្តីពីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នឹងជួយគាំទ្រដល់ដំណើរការអភិវឌ្ឍគុណសម្បទារបស់សិស្ស ជំរុញការអភិវឌ្ឍផ្នែកពុទ្ធិ ផ្តល់មូលដ្ឋានជាក់លាក់ក្នុងការរៀបចំផែនការសិក្សាការកំណត់គោលដៅអាជីពដល់សិស្ស ចូលរួមចំណែកជួយដោះស្រាយបញ្ហាភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មក្នុងទីផ្សារការងារកម្ពុជា នាពេលបច្ចុប្បន្ន។ គោលនយោបាយនេះ នឹងផ្តល់វិភាគទានជាវិជ្ជមានដល់ប្រព័ន្ធអប់រំនៅកម្ពុជា ដោយគ្របដណ្តប់លើទិដ្ឋភាពនៃការគាំទ្រភាពរីកចម្រើនរបស់សិស្សចាប់ពីកម្រិតមធ្យមសិក្សា រហូតដល់ឧត្តមសិក្សា ជួយកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស និងផ្តល់ការគាំពារដល់យុវជនក្រៅសាលា ព្រមទាំងបណ្តុះស្មារតីស្រឡាញ់ការសិក្សា អាជីពការងារ និងគំនិតសហគ្រិនភាពដល់សិស្សផ្សារភ្ជាប់ទៅនឹងមូលដ្ឋានជំនាញទន់ ដែលជាតម្រូវការចាំបាច់នៅពេលបំពេញការងារ។

ចក្ខុវិស័យ គោលបំណងនិងគោលដៅ ផែនការយុទ្ធសាស្ត្រ និងយន្តការអនុវត្ត ដែលបានបង្ហាញក្នុងគោលនយោបាយនេះ គឺជាក្របខណ្ឌការងារជាក់លាក់មួយ ដែលនឹងជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតគ្រឹះស្ថានសិក្សា ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡាសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះនាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធដែលបានខិតខំ និងរួមចំណែកកសាងគោលនយោបាយដ៏មានសារៈសំខាន់នេះ។ ក្រសួងសង្ឃឹម និងជឿជាក់ថាអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សហគមន៍ អង្គការជាតិ និងអន្តរជាតិ នឹងចូលរួមគាំទ្រសហការផ្សព្វផ្សាយអនុវត្តគោលនយោបាយនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១១រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បានរៀបចំយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅឆ្ពោះទៅកសាងមូលដ្ឋានសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដោយផ្តោតជាសំខាន់លើការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណខាងលើ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពីការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផ្តោតអាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនជីវិតឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាកម្រិតមធ្យមសិក្សា ក្នុងឆ្នាំ២០១៥ តាមរយៈការជ្រើសរើសគ្រូមុខវិជ្ជាមកបំប៉នសមត្ថភាពលើការអនុវត្តកម្មវិធីនេះ។ ត្រឹមឆ្នាំ២០២១ មានគ្រឹះស្ថានមធ្យមសិក្សាសាធារណៈចំនួន ៦៥ នៅរាជធានី ខេត្ត ចំនួន១២ បាននិងកំពុងដំណើរការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដោយមានគ្រូប្រឹក្សាតាមសាលារៀន ចំនួន១៦៤នាក់ ស្រី ៧៤នាក់។ សិស្សដែលទទួលផលដោយផ្ទាល់ពីការអនុវត្តកម្មវិធីនេះ ប្រមាណជា ៤០,០០០ នាក់/ឆ្នាំសិក្សា ស្រី ៥៥ ភាគរយ ដែលក្នុងនោះសេវាផ្តល់ប្រឹក្សាទល់មុខប្រមាណជា ១,០០០ នាក់/ឆ្នាំសិក្សា ស្រី ៦៥ ភាគរយ។ ផ្អែកលើរបាយការណ៍ស្រាវជ្រាវស្តីពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ឆ្នាំ២០២១ របស់អង្គការជំនួយព្រះវិហារហ្វាំងឡង់ប្រចាំប្រទេសកម្ពុជា បង្ហាញថា កម្មវិធីមគ្គុទ្ទេសក៍ អាជីពនិងការផ្តល់ប្រឹក្សា បានរួមចំណែកជំរុញឱ្យមានការប្រែប្រួលជាវិជ្ជមាននៅកម្រិតសាលារៀនដូចជា៖

- អត្រាបោះបង់ការសិក្សា និងអត្រាអវត្តមានក្នុងថ្នាក់របស់សិស្សថយចុះ
- សិស្សអាចរៀបចំផែនការសិក្សា និងអាជីព និងមានលទ្ធភាពស្វែងរកព័ត៌មានពីប្រភពផ្សេងៗ
- ឥរិយាបថសិក្សារៀនសូត្រ និងអាកប្បកិរិយារបស់សិស្សប្រែប្រួលជាវិជ្ជមាន ដោយសិស្សស្គាល់ពីតួនាទីខ្លួនឯង មានគោលដៅច្បាស់លាស់ក្នុងការសិក្សា មានភាពក្លាហានច្រើនជាងមុន ចេះសហការគ្នាជួយគ្នា ដែលជំរុញឱ្យលទ្ធផលនៃការសិក្សាកាន់តែប្រសើរ
- សិស្សទទួលបានជំនួយផ្នែកប្រឹក្សា ដើម្បីកំណត់ជម្រើសអាទិភាពនៃការដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធការសិក្សា និងបញ្ហាផ្ទាល់ខ្លួន
- គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សហគមន៍ មាតាបិតា ចូលរួមគាំទ្រលើដំណើរការសិក្សារៀនសូត្ររបស់សិស្សជាងមុន។

ដោយមើលឃើញអំពីសក្តានុពលរបស់កម្មវិធី ក្នុងការជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សក៏ដូចជាការសម្របសម្រួលផ្នែកប្រព័ន្ធអន្តរាគមន៍សម្រាប់យុវជន តាមរយៈសកម្មភាពមគ្គុទ្ទេសក៍ក្នុងថ្នាក់ សកម្មភាព

ប្រឹក្សាទល់មុខ កិច្ចការបណ្តាញរបស់គ្រូ និងការដឹកនាំសកម្មភាពតម្រង់ទិសនានា ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដើម្បីជាផែនទីចង្អុលផ្លូវសម្រាប់ការអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមគ្រឹះស្ថានសិក្សា។ គោលនយោបាយនេះ បានរំលេចចេញនូវក្របខណ្ឌការងារចាំបាច់ក្នុងការរៀបចំសកម្មភាពគាំទ្រ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការរៀនសូត្រគាំទ្រដោយផ្ទាល់លើតវិយាបថសិក្សា និងការត្រៀមខ្លួនសម្រាប់ទីផ្សារការងាររបស់សិស្សនៅតាមសាលារៀនក្នុងយុគសម័យបច្ចេកវិទ្យាដ៏ជឿនលឿន។

## ២. ចក្ខុវិស័យ

គោលនយោបាយស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានចក្ខុវិស័យអភិវឌ្ឍយុវជនកម្ពុជាឱ្យមានគុណសម្បទា ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ ប្រកបដោយសុខដុមនីយកម្មវិជ្ជាជីវៈ។

## ៣. គោលបំណង និងគោលដៅ

គោលនយោបាយស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានគោលបំណងរួមចំណែកកសាង និងពង្រឹងគុណសម្បទាយុវជនលើការរៀបចំផែនការសិក្សា ផែនការអាជីព និងជំនាញទន់ ដើម្បីចាប់យកជំនាញវិជ្ជាជីវៈ ឆ្លើយតបនឹងទេពកោសល្យពីកំណើត និងបរិបទទីផ្សារការងារ នាយុគសម័យបច្ចេកវិទ្យា។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ គោលនយោបាយស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានគោលដៅដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមគ្រឹះស្ថានសិក្សា
- រៀបចំប្រព័ន្ធគាំទ្រកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- បង្កើតយន្តការអនុវត្ត និងវាយតម្លៃកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- អភិវឌ្ឍសមត្ថភាពគ្រូប្រឹក្សាតាមសាលារៀន និងអ្នកពាក់ព័ន្ធ
- ផ្តល់សេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាដល់យុវជន ។

## ៤. យុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ត្រូវយកចិត្តទុកដាក់លើយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

### ៤.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

- អភិវឌ្ឍលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា

- ពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា
- រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវប្រសិទ្ធភាព និងសង្គតិភាព
- រៀបចំយន្តការវាយតម្លៃសមិទ្ធផលស្នាដៃ និងផ្តល់ការលើកទឹកចិត្ត
- កសាងផែនការសកម្មភាព ដោយកំណត់អ្នកទទួលខុសត្រូវច្បាស់លាស់។

### ៤.២. អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាល និងការទទួលស្គាល់គ្រូប្រឹក្សាតាមសាលារៀន

- រៀបចំប្រព័ន្ធបណ្តុះបណ្តាលគ្រូប្រឹក្សាតាមសាលារៀន
- រៀបចំកម្មវិធីបំប៉នសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូប្រឹក្សាតាមសាលារៀន និងអ្នកពាក់ព័ន្ធ
- រៀបចំយន្តការអន្តរាគមន៍ផ្នែកបច្ចេកទេសដល់គ្រូប្រឹក្សាតាមសាលារៀន
- រៀបចំប្រព័ន្ធទទួលស្គាល់គុណវុឌ្ឍិគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូប្រឹក្សាតាមសាលារៀន។

### ៤.៣. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា

- រៀបចំកម្មវិធីណែនាំអំពីសញ្ញាណទូទៅពាក់ព័ន្ធនឹងអាជីព និងមុខរបរ
- រៀបចំកម្មវិធីតាមដានអំពីចំណង់ចំណូលចិត្ត ឧបនិស្ស័យ និងទំនោរវិជ្ជាជីវៈកុមារ។

### ៤.៤. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតមធ្យមសិក្សា និងយុវជនក្រៅសាលា

- កសាងសមត្ថភាពសិស្ស និងយុវជនក្រៅសាលា លើកម្មវិធីអប់រំបំណិនជីវិត និងសហគ្រិនភាព
- ជំរុញការអប់រំតម្រង់ទិសសិស្ស និងយុវជនក្រៅសាលា ក្នុងការជ្រើសរើសផ្លូវសិក្សា អាជីព និងមុខរបរ
- លើកកម្ពស់ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍ក្នុងថ្នាក់ ប្រឹក្សាទល់មុខ និងការងារបណ្តាញ
- លើកកម្ពស់ឱកាសចូលទីផ្សារការងារនិងលទ្ធភាពទទួលបានការងាររបស់សិស្សនិងយុវជនក្រៅសាលាប្រកបដោយប្រសិទ្ធភាព។

### ៤.៥. អភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅកម្រិតឧត្តមសិក្សា

- ជំរុញការគាំទ្រផ្នែកបញ្ញានិងស្មារតី ដើម្បីឱ្យនិស្សិតទទួលបានបទពិសោធ ចំណេះដឹង និងជំនាញច្បាស់លាស់
- លើកកម្ពស់សមត្ថភាពនិស្សិតក្នុងការបំពេញការងារប្រកបដោយផលិតភាពខ្ពស់ និងអាចរកប្រាក់ចំណូលបានសមរម្យ

- លើកកម្ពស់ការអនុវត្តកម្មវិធីប្រឹក្សាទល់មុខនិងការងារបណ្តាញ ដើម្បីផ្តល់ឱកាសដល់និស្សិតចូលទីផ្សារការងារនិងមានលទ្ធភាពទទួលបានការងារសមរម្យ។

### ៤.៦. ពង្រឹងការចូលរួម គាំទ្រ និងលើកទឹកចិត្តពីអ្នកពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី

- ធានាថាមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ផ្តល់ការគាំទ្រផ្នែកស្មារតី បច្ចេកទេស និងធនធាន ដល់គ្រូប្រឹក្សាតាមសាលារៀន ដើម្បីដំណើរការរៀបចំកម្មវិធីក្នុងសាលារៀន
- សហការជាមួយដៃគូអភិវឌ្ឍដើម្បីពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ជំរុញកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថានសិក្សាជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និស្សិត សហគមន៍ អាជ្ញាធរពាក់ព័ន្ធ សហគ្រាស គ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា។

## ៥. ផែនការសកម្មភាព

ដើម្បីសម្រេចនូវយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោមៈ

### ៥.១. ការបង្កើតយន្តការ

- បង្កើតគណៈកម្មការដឹកនាំ គ្រប់គ្រង អនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតអនុគណៈកម្មការនានាដើម្បីសម្របសម្រួលដំណើរការអនុវត្តកម្មវិធី
- បង្កើតសហគមន៍សិក្សាវិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា
- កំណត់លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសតួនាទីភារកិច្ចនិងក្រមសីលធម៌វិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន។

### ៥.២. ការបង្កើតក្របខណ្ឌគតិយុត្ត

- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានប្រសិទ្ធភាព
- គណៈកម្មការ អនុគណៈកម្មការថ្នាក់ជាតិ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា

- គណៈកម្មការ អនុគណៈកម្មការថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ប្រធានអង្គភាពថ្នាក់ក្រោមជាតិ
- គណៈកម្មការ អនុគណៈកម្មការកម្រិតគ្រឹះស្ថានសិក្សា ត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ប្រធានគ្រឹះស្ថានសិក្សាសាមី។

### ៥.៣. ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីគាំទ្រយន្តការនិងដំណើរការសកម្មភាពតាមយុទ្ធសាស្ត្រនីមួយៗ គោលនយោបាយនេះត្រូវមានថវិកាដែលបានមកពីប្រភពៈ

- ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ថវិកាដៃគូអភិវឌ្ឍ វិភាគទានពីវិស័យឯកជន សហគមន៍ ព្រមទាំងថវិកាមកពីប្រភពផ្សេងៗទៀត។

### ៥.៤. ការបណ្ដុះបណ្ដាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្ដីពី មគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ត្រូវយកចិត្តទុកដាក់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សលើការងារបច្ចេកទេស ការគ្រប់គ្រងដឹកនាំ ការរៀបចំ ផែនការ និងការកសាងឯកសារ តាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការងារមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា។

### ៥.៥. ដំណើរការអនុវត្តគម្រោង

ការរៀបចំផែនការបណ្ដុះបណ្ដាលគ្រូប្រឹក្សាតាមសាលារៀន ការកសាងសមត្ថភាព ការរៀបចំសកម្មភាពគាំទ្រដល់ការពង្រីកកម្មវិធី និងការលើកកម្ពស់កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា នឹងត្រូវរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ។ ផែនការនេះ ត្រូវស្របតាមចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងត្រូវឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

## ៦. ការពិនិត្យតាមដាន និងការវាយតម្លៃ

អង្គភាពពាក់ព័ន្ធត្រូវមានយន្តការវាយតម្លៃ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពនៃកម្មវិធីយ៉ាងទៀងទាត់ ដើម្បីធានាប្រសិទ្ធភាព ភាពឆ្លើយតបនៃកម្មវិធី និងកែលម្អការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សានៅតាមគ្រឹះស្ថានសិក្សា។

## ៧. សេចក្ដីសន្និដ្ឋាន

គោលនយោបាយស្ដីពី មគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា បានកំណត់នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំខាន់ៗ ដើម្បីគាំទ្រដំណើរការដឹកនាំ គ្រប់គ្រង រៀបចំ និងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការ

ផ្តល់ប្រឹក្សានៅតាមគ្រឹះស្ថានសិក្សា ប្រកបដោយនិរន្តរភាព។ ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាគ្រប់អង្គភាពពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល និងបុគ្គលិកអប់រំទាំងអស់ នឹងចូលរួមគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយនេះ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់៕

# សទ្ទានុក្រម

**ការផ្តល់ប្រឹក្សា** សំដៅដល់ដំណើរការដែលពាក់ព័ន្ធនឹងការបង្ហាញផ្លូវជាជម្រើស ការណែនាំ ការបង្ហាញពីវិធីសាស្ត្រ ការដោះស្រាយបញ្ហា ដែលមានលក្ខណៈជាបុគ្គល ឬជាក្រុម ដើម្បីជួយឱ្យនរណាម្នាក់អាចប្រើប្រាស់អស់នូវ សក្តានុពលផ្ទាល់ខ្លួន ក្នុងការបំពេញតួនាទីជាពលរដ្ឋពេញលេញ។

**គុណសម្បទា** សំដៅដល់ការអភិវឌ្ឍវឌ្ឍិវិជ្ជា វឌ្ឍិបំណិន និងវឌ្ឍិចរិយាដែលជាយានសម្រាប់ដឹកនាំបុគ្គលម្នាក់ៗឱ្យឈានទៅជោគជ័យ។

**គ្រូប្រឹក្សាតាមសាលារៀន** សំដៅដល់គ្រូទទួលបន្ទុករៀបចំ និងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមសាលារៀន ចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់ឧត្តមសិក្សា ហើយដែលត្រូវបានធ្វើការបណ្តុះបណ្តាល ឬរៀក្រឹតការដោយអង្គភាពជំនាញក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**គ្រូឧទ្ទេសថ្នាក់ជាតិ** សំដៅដល់ក្រុមគ្រូឧទ្ទេសក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ដែលបានទទួលការបណ្តុះបណ្តាល និងទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**គ្រឹះស្ថានសិក្សា** សំដៅដល់អង្គភាពផ្តល់សេវាអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ដោយរាប់បញ្ចូលសាលារៀន វិទ្យាស្ថាន សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិត។

**មគ្គុទ្ទេសក៍** សំដៅដល់ការជួយជ្រោមជ្រែងពេញលេញជាលក្ខណៈបុគ្គល ទៅដល់អ្នកប្រើប្រាស់សេវាដើម្បីគេអាចពង្រីកការស្វែងយល់អំពីខ្លួនឯង និងអ្នកដទៃ។ វាមានលក្ខណៈជាដំណើរការពេញមួយជីវិត ដែលទាក់ទងនឹងតម្រូវការអភិវឌ្ឍរបស់បុគ្គលម្នាក់ៗ។

**មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា** សំដៅដល់ចង្កោមកម្មវិធី ដែលជួយត្រួសត្រាយផ្លូវ និងផ្តល់ការគាំទ្រដល់កុមារយុវជនលើដំណើរការសិក្សារៀនសូត្រ ការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សា អាជីព និងមុខរបរការរៀបចំ ឥរិយាបថ បំពេញការងារ ដោយផ្អែកលើទេពកោសល្យ សមត្ថភាព ចំណាប់អារម្មណ៍បំណិន និងសក្តានុពលទីផ្សារការងារ។

**មុខរបរ** សំដៅដល់ការងារទាំងឡាយដែលកិច្ចការ ឬភារកិច្ចចម្បងៗត្រូវបំពេញឱ្យមានលក្ខណៈស្រដៀង ឬពាក់ព័ន្ធគ្នាខ្លាំង។

**យុវជនក្រៅសាលា** សំដៅដល់ក្រុមយុវជនក្នុងវ័យសិក្សាចាប់ពីមធ្យមសិក្សាបឋមភូមិឡើងទៅ ដែលប្រឡងធ្លាក់ ឬមិនអាចបន្តចូលរៀននៅក្នុងប្រព័ន្ធអប់រំចំណេះទូទៅ ឬប្រព័ន្ធអប់រំបច្ចេកទេស។

**សហគមន៍សិក្សាវិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន** សំដៅដល់ក្រុមគ្រូប្រឹក្សាតាមសាលារៀននិងអ្នកពាក់ព័ន្ធ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលផ្លូវការអំពីកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្រុមនេះមានភារកិច្ចចែករំលែកបទពិសោធ ចំណេះដឹង និងជំនាញរវាងគ្នានិងគ្នា ក្នុងន័យអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូប្រឹក្សាតាមសាលារៀនជាប្រចាំ។

**សុខដុមនីយកម្មវិជ្ជាជីវៈ:** សំដៅដល់ភាពស្រុះស្រួលខាងផ្លូវចិត្ត ភាពម្ចាស់ការ ការទទួលខុសត្រូវ ភាពបត់បែនក្នុងស្មារតីជំរុញឱ្យមានផលិតភាពខ្ពស់នៅកន្លែងបំពេញការងារ។

**អាជីព** សំដៅដល់ការបំពេញការងារក្នុងរយៈពេលដ៏យូរ ដែលផ្តើមចេញពីគោលបំណងជាក់លាក់ពេញមួយជីវិត ឬឆ្លុះបញ្ចាំងពីបែបផែនជីវិតរបស់បុគ្គលម្នាក់ក្នុងការងារនោះ។